## ជ័យលាភីលេខ១ ផ្នែកតែងនិពន្ធ

## «ពានរង្វាន់សម្តេចតេជោ ហ៊ុន សែន»

### អបអរសាទរ ទិវាជាតិអំណានលើកទី៥ ១១ មីនា ២០២០


**យុវតី ហេង មៀនមៀន**

*ជាសិស្សថ្នាក់ទី ១២ នៃវិទ្យាល័យសម្តេចឪ ខេត្តតាកែវ*


**ចំណងជើងកំណាព្យ៖ «និស្ស័យស្នេហ៍អំណាន»**

(កំណាព្យបទ ពាក្យប្រាំពីរ)

១- នេះនឹងថ្លាថ្លែងចែចរចា យុវតុលាប្រាជ្ញាវៃ
រៀនទីដប់ពីរពិតប្រពៃ គោរពវិន័យសិស្សសាលា។

២- ជាស៊ីមតាកែវវិទ្យាល័យ បណ្ដុះនិស្ស័យស្វ័យសិក្សា
បញ្ញត្តិតូចធំជុំតម្រា ចំណេះបញ្ញាថ្លាប្រាកដ។

៣- ព្រោះតែតុលាឧស្សាហ៍អាន ជំនាញចំណានបានហ្មត់ចត់
ត្រាប់គ្រូជីតាអានគិតកត់ អំណានអំណត់កត់និស្ស័យ។

៤- ងាកមកនិយាយពីនីតា សិស្សស្រីសិក្សាបានថ្លាថ្លៃ
ព្រះស៊ីសុវត្ថិវិទ្យាល័យ នាងរៀនរាល់ថ្ងៃតម្លៃថ្កាន។

៥- តែងមើលសិស្សច្បងផងពូកែ អានបានហួរហែស្នេហ៍អំណាន
ខិតខំតម្រាប់ត្រាប់តាមដាន រិះរករៀនអានបានបវរ។

៦- ជួនជាទ្វារបណ្ណាល័យជាតិ បើកទទួលទៀតតាំងពិព័រណ៌
សៀវភៅសិក្សាតម្រាល្អ នីតាអំណរតនិស្ស័យ។

៧- ណែនាំមិត្តភក្តិជាក់ប្រញាប់ នៅភ្នំពេញស្រាប់ចាប់កែខៃ
ទៅទស្សនាបណ្ណាល័យ សៀវភៅនៅដៃថ្ងៃអំណាន។

៨- ចំណែកតុលានៅឯស្រែ ចង់ចូលរួមដែរឥតបែរខាន
មកទិញសៀវភៅយកទៅអាន រួចដើរកំសាន្តបានពេលខ្លី។

៩- និស្ស័យដឹកដៃថ្ងៃជំនួប តុលាចួនជួបនីតាស្រី
ត្រង់ស្តង់ពិព័រណ៍លេខប្រាំបី សៀវភៅតាំងថ្មីអានជិតគ្នា។

១០- លុះបិទបញ្ចប់កម្មវិធី ពួកគេមូលមីរទីវិជ្ជា
ខិតខំសិក្សាឥតអេរា បាក់ឌុបគ្រប់គ្នាជាប់ថ្លៃថ្លា។

១១- នីតាសម្រេចប្តេជ្ញាច្បាស់ រៀនអក្សរសាស្ត្រខ្មែរនិស្ស័យ
និស្សិតមហាវិទ្យាល័យ រៀនគ្រប់យប់ថ្ងៃថ្ងៃរៀបចំ។

១២- បណ្ណាល័យជាតិឆ្លៀតចូលអាន បន្តអំណានបានឧត្តម
អក្សរចារឹកថ្មីកច្បាប់ក្រម ស្រាវជ្រាវខិតខំផ្សំវិជ្ជា។

១៣- និយាយអំពីតុលាវិញ មករៀនភ្នំពេញពិតពុះពារ
រៀនសាលាបច្ចេកវិទ្យា នៃកម្ពុជាវិទ្យាស្ថាន។

១៤- តែងតែនៅបណ្ណាល័យជាតិ ស្រាវជ្រាវឆ្លាស់ឆ្លៀតឥតឃ្លាតអាន
ចួបជួននីតាស្រស់កល្យាណ រីករាយហួសស្មានបានវេលា។

១៥- វាសនាកំណត់កត់ចំណាន ពួកគេពីរប្រាណបានស្គាល់គ្នា
បន្តរៀនអានបានគ្រប់គ្រា ផ្ដើមផ្ដល់វិជ្ជាគ្នាបន្ត។

១៦- រហូតបញ្ចប់ការសិក្សា ថ្នាក់បរិញ្ញាចិត្តអំណរ
នីតាជាប់ជាក់អ្នកគ្រូល្អ បង្រៀនស្មោះសរអក្សរសាស្ត្រ។

១៧- ដល់សិស្សគ្រប់គ្នាបានយល់ដឹង ចេះគិតប្រែងប្រឹងថ្នឹងថ្លែងច្បាស់
ជាប់ជ័យលាភីដ៏ទីត្រចះ ត្រចង់ល្អល្អះទិវាអាន។

១៨- រីឯតុលាការងារល្អ ជាវិស្វករដ៏ចំណាន
សាងសង់ហេដ្ឋាពិតច្រើនថ្កាន ជាតិចម្រើនបានថ្កានក្រាស់ក្រៃ។

២០- និស្ស័យស្នេហាថ្លាប្រាកដ ទេព្ដាកំណត់កត់និស្ស័យ
គេទាំងពីរប្រាណបានដឹកដៃ សាងស្នេហ៍ថ្លើមថ្លៃថ្ងៃរៀបការ។

២១- នេះពិតអំណាចនៃអំណាន សាងស្នេហ៍សុខសាន្តពីកាយា
រវាងតុលានិងនីតា និស្ស័យស្នេហាចាចំណាំ។

២២- នីតាចាចែងតែងកាព្យ ឱ្យសិស្សគ្រប់គ្នាជាបណ្ដាំ
ប្រយោជន៍អំណានបានចងចាំ ដុះដាលផ្សះផ្សាំដាំតម្លៃ។

២៣- រួមលើកស្ទួយយុទ្ធនាការ ថ្នាក់ជាតិថ្លៃថ្លាអានរាល់ថ្ងៃ
អានទាំងអស់គ្នាជានិស្ស័យ ចេះចាំថ្លាថ្លៃក្រៃសន្លឹក។

២៤- ជាតិជាពន្លកកូមរា ក្រេបលម្អងផ្កាថៃក្បាលទឹក
រីសួនបុប្ផាផ្កាសន្លឹក ដោយថៃល្ងាចព្រឹកស្រោចទឹកវា។

២៥- ជាតិជាមនុស្សខ្ពស់បញ្ញា រីកបែកដូចផ្កាសាយគន្ធា
ដោយសារការអានបានគ្រប់គ្រា ក្បួនច្បាប់នានាជាលំអាន។

២៧- អានបានរៀសឈ្លាសវាងវៃ ពុទ្ធិវិន័យប្រពៃថ្កាន
បញ្ញារីករស់ខ្ពស់ចំណាន ចំណេះហំហានបានបណ្ឌិត។

២៨- ចេះចាំតម្រាការនិពន្ធ ទាញទុកជាទុនធនគំនិត
ត្រួសត្រាយត្រឹមត្រូវផ្លូវជីវិត ប្រសើរស័ក្តិសិទ្ធិពិតសុខសាន្ត។

២៩- បណ្ដុះឆន្ទៈអ្នកសិក្សា ស្រាវជ្រាវតែម្រាតម្រង់អាន
សិលាចារឹកស្លឹករឹតថ្កាន ក្រឹត្យក្រមអំណានអានគ្រប់គ្រា។

៣០- ទាំងវិទ្យាសាស្ត្រច្បាស់សង្គម បញ្ញត្តិតូចធំផ្ដុំគាំពារ
អំណានតតបស្របមាគ៌ា អានទាំងអស់គ្នារៀងរាល់ថ្ងៃ។

៣១- អំណាចអំណានថ្កានគំនិត ផ្ដើមផ្ដល់ផលពិតប្រឌិតច្នៃ
នវានុវត្តន៍ស្នាត់ថ្លាថ្លៃ តាមទាន់វិស័យវិទ្យាសាស្ត្រ។

៣២- យុគអាយស៊ីធីឌីជីថល អនឡាញហ្វូហ្វលផលប្រើប្រាស់
ទាមទារតាមដានអានឱ្យច្បាស់ ទ្រឹស្ដីថ្មីចាស់ផ្លាស់បន្ត។

៣៣- បដិវត្តន៍ឧស្សាហកម្ម ទីបួនចងចាំដាំដុះល្អ
ក្នុងថ្នាលអំណានបានបវរ ដូចបុប្ផាករីកល្អពិត។

៣៤- ជូននេះរិះអានថ្កានបញ្ញា ស្រាវជ្រាវសិក្សាថ្លាគំនិត
ចេះបង្កើនថ្មីច្នៃប្រឌិត ជួយជាតិយោងយិតឫទ្ធិរុងរឿង។

## ជ័យលាភីលេខ២ ផ្នែកតែងនិពន្ធ

## «ពានរង្វាន់សម្តេចតេជោ ហ៊ុន សែន»

## អបអរសាទរ ទិវាជាតិអំណានលើកទី៥ ១១ មីនា ២០២០


**យុវតី ខួន សុធារីកា**

*ជាសិស្សថ្នាក់ទី ១១ នៃវិទ្យាល័យ សម្តេចជាស៊ីមអង្គរជ័យ ខេត្តកំពត*


## ចំណងជើងកំណាព្យ៖ អំណាចនៃអំណាន

(អត្ថបទ ពាក្យរាយ)

ទីក្រុងភ្នំពេញជាទីក្រុងដ៏ស្រស់ឆើតឆាយ អមសម្រស់សដោយអគារខ្ពស់ៗ និងដងទន្លេយ៉ាងល្អសោភាគួរជាទីសុខសាន្តនៃខេមរជន និងជនទាំងឡាយទាំងពួង។ ក្នុងយុគសម័យទំនើបនេះភ្នំពេញគឺជាកន្លែងពេញនិយមបំផុត និងសម្បូរទៅដោយមនុស្សរស់នៅយ៉ាងច្រើនកុះករ។ប្រជាជនជាច្រើនលាននាក់បានមករស់នៅ និងប្រកបរបរនៅក្នុងទីក្រុងមួយនេះ ក្នុងនោះក៏មានគ្រួសារតូចមួយដែលទើបតែផ្លាស់មកពីទីជនបទមកអាស្រ័យ និងរកស៊ីចិញ្ចឹមជីវិតនៅទីក្រុងនេះផងដែរ។ គ្រួសារនោះមានសមាជិកពីរនាក់ឪពុក និងកូនរស់នៅក្រោមជំបូលផ្ទះជួលមួយកន្លែងក្បែរមន្ទីរពេទ្យទីក្រុងភ្នំពេញ ហើយឪពុកជាមេគ្រួសារប្រកបអាជីពជាអ្នករត់ម៉ូតូឌុបដើម្បីរកប្រាក់មកផ្គត់ផ្គង់គ្រួសារ។ ឯកូនប្រុសរបស់គាត់ឈ្មោះ **ឧត្តម** ជាសិស្សរៀននៅអនុវិទ្យាល័យ មានវ័យដប់បីឆ្នាំ គេនេះជាមនុស្សខ្ជិល មិនយកចិត្តទុកដាក់រៀនសូត្រ ស្អប់ការអានសៀវភៅ មួយថ្ងៃៗគិតតែពីដើរលេង មិនខ្វល់ខ្វាយពីអ្វីៗទាំងអស់ ទៅរៀនឱ្យតែបាត់ពីផ្ទះ យកលុយចាយឥតអំពើ មកដល់ផ្ទះបោះសៀវភៅចោលដូចរបស់គ្មានន័យ គ្មានតម្លៃ បន្តិចសោះឡើយ។ បែបនេះហើយទើបធ្វើឱ្យការសិក្សារបស់គេទទួលបានលទ្ធផលមិនល្អជារៀងរាល់ខែ រហូតដល់លោកគ្រូហៅគេទៅណែនាំជាច្រើនលើកច្រើនសារ ក៏នៅតែមិនស្តាប់តាម ឬ កែខ្លួនឡើងវិញនោះឡើយ លោកគ្រូខឹងខ្លាំងណាស់គាត់ក៏សម្រេចចិត្តថានឹងយកដំណឹងនេះទៅប្រាប់ដល់អាណាព្យាបាលរបស់**ឧត្តម**។ គាត់បានទៅដល់ផ្ទះរបស់**ឧត្តម** ហើយប្រាប់ដំណឹងនេះទៅឪពុករបស់គេយ៉ាងលម្អិត បន្ទាប់ពីដឹងរឿងអស់ហើយឪពុករបស់ក្មេងប្រុសតូចមានចិត្តរន្ធត់ជាខ្លាំង គាត់ពុំនិកស្មានថាកូនរបស់គាត់ប្រព្រឹត្តិអំពើបែបនេះទេ។ ពីមួយថ្ងៃទៅមួយថ្ងៃទឹកចិត្តអ្នកជាឪពុកចេះតែគិតខ្វល់ពីកូន ធ្វើឱ្យគាត់ពិបាកចិត្តគេងពុំលក់ធ្លាក់ខ្លួនឈឺទៀតផង។ ចំណែឯកូនក៏នៅតែបន្តការគេចម៉ោងរៀនទៅដើរលេងរាល់ថ្ងៃ លុះដល់ល្ងាចមួយពេលដែលគេត្រលប់មកផ្ទះវិញ ឃើញថាឪពុកមិនទាន់មកវិញទេ ក្មេង**ឧត្តម** គិតថា "ប្រហែលជាគាត់ជាប់រវល់ដឹកភ្ញៀវច្រើនហើយ បន្តិចទៀតប៉ាប្រាកដជាមកដល់ហើយ យកអាហារឆ្ងាញ់ៗមកឱ្យខ្ញុំមិនខានទេ"។ គិតរួច**ឧត្តម**ក៏រត់ស្ទុះឡើងទៅបន្ទប់បម្រុងនឹងសម្រាក ប៉ុន្តែគ្រាន់តែដាក់ក្បាលដល់ខ្នើយភ្លាមទូរស័ព្ទក៏រោទ៍ឡើង ទីង! ទីង! ទីង! កុមារតូចទទួលរួចនិយាយ៖

-«ជម្រាបសួរបាទ! សុំទោសលោកពូជានរណា ហេតុអ្វីបានជាយកទូរស័ព្ទរបស់ប៉ាខ្ញុំ មកនិយាយអីចឹង?»

-លោកពូនោះតប «បាទ៎ ប្អូនជាកូនរបស់គាត់ឬ?»

-**ឧត្តម** តប «បាទ៎! គាត់ជាឪពុករបស់ខ្ញុំ»

-លោកពូនិយាយបន្ត «សូមប្អូនប្រញាប់មកមន្ទីរពេទ្យមន្តិចមក ព្រោះឪពុកប្អូនគាត់ជួបគ្រោះថ្នាក់ចរាចរណ៍ណ៎ាប្អូន»។

ស្តាប់ចប់កុមារតូចហាក់ស្លត់ស្មារតី បាត់អស់វិញ្ញាណក្នុងខ្លួន ទឹកនេត្រាស្រក់មករហាមដោតពេញលើផែនថ្ពាល់ពណ៌ផ្កាឈូកស្រស់ កាយរបស់គេស្ទុះរត់យ៉ាងលឿនបំផុតសំដៅទៅមន្ទីរពេទ្យ។ ពេលទៅដល់ **ឧត្តម** បានត្រឹមរង់ចាំមុខបន្ទប់សង្គ្រោះបន្ទាន់ ឱនមុខចុះយំស្រែកស្តាយក្រោយ។ ក្នុងវេលានោះស្រាប់តែមានបុរសម្នាក់មកអោបគេពីក្រោយ

ហើយពោលតិចៗថា«កុំបារម្មណ៍ប៉ារបស់កូនប្រុសនឹងមិនអីទេ»។ មួយសន្ទុះក្រោយមក គ្រូពេទ្យក៏បានចេញមកហើយប្រាប់ថា «អ្នករបួសរួចផុតពីគ្រោះថ្នាក់ហើយ តែនៅមិនទាន់ដឹងខ្លួននៅឡើយទេ ត្រូវរង់ចាំមើលអាការបន្តទៀតសិន»។ នារាត្រីដ៏អួរអាប់ក្នុងបន្ទប់អ្នកជំងឺមានបុរសវ័យកណ្ដាលម្នាក់ និងកុមារតូចម្នាក់កំពុងនិយាយជាមួយគ្នាហាក់ដូចជាស្ថិតក្នុងស្ថានភាពពុំសូវល្អសោះ។ ក្មេងប្រុសនិយាយបណ្ដើរទឹកភ្នែកស្រក់ចុះបណ្ដើរ «លោកគ្រូ ខ្ញុំពិតជាកូនដ៏អាក្រក់បំផុត ព្រោះខ្ញុំពុំដែលខ្វល់ពីប៉ា ថាលោកបានលះបង់ដើម្បីរូបកូនម្នាក់នេះបែបណានោះទេ លោកគ្រូ» គេនិយាយបន្ត «ខ្ញុំពិតជាចង់សុំទោសគាត់ ចង់កែខ្លួនខិតខំប្រឹងប្រែងរៀន ដើម្បីតបស្នងគាត់វិញណាស់»។ លោកគ្រូនិយាយ «ល្អណាស់កូនប្រុស ឯងអាចកែខ្លួនជាថ្មីវិញបានណា វាមិនទាន់យឺតពេលនេះទេកូនសម្លាញ់»។ ចាប់តាំងពីពេលនោះមក **ឧត្ដម** តូច បានតាំងចិត្តមើលថែឪពុកយ៉ាងល្អរហូតដល់បានធូរស្បើយ ហើយគេខិតខំប្រឹងប្រែងរៀនសូត្រ ស្ដាប់ដំបូន្មានលោកគ្រូអ្នកគ្រូ មិនតែប៉ុណ្ណោះ **ឧត្ដម** បានយកពេលទំនេររបស់គេទៅអានសៀវភៅ លែងយកទៅធ្វើរឿងឥតប្រយោជន៍ទៀតហើយ។ កុមារតូចបានទទួលលទ្ធផលល្អក្នុងការរៀនសូត្រជារៀងរាល់ខែ ឃើញដូចនេះលោកគ្រូ អ្នកគ្រូ ក៏បានកោតសរសើរគេមិនដាច់ពីមាត់ ហើយថែមទាំងផ្ដល់នូវសៀវភៅជាច្រើនដល់**ឧត្ដម** ព្រោះចង់ឱ្យ**ឧត្ដម**រៀនកាន់តែប្រសើរជាងមុនទៀត។ ពិតណាស់បំណិននៃការអានបានធ្វើឱ្យ**ឧត្ដម**មានបញ្ញាមុតថ្លា មានគំនិតទូលំទូលាយ ចេះស្រាវជ្រាវ និងជម្រុញឱ្យកុមារវ័យក្មេងម្នាក់នេះមានមហិច្ឆតាចង់ក្លាយជា អ្នកបង្កើតថ្មីនូវវត្ថុដែលមានបច្ចេកវិទ្យាទំនើបៗ ដ៏ល្បីល្បាញម្នាក់។ បំណងនេះធ្វើឱ្យគេកាន់តែខិតខំស្រាវជ្រាវយ៉ាងយកចិត្តទុកដាក់បំផុតហើយជាសំណាងរបស់ឧត្ដមដែលទទួលបាននូវការជួយនិងលើកទឹកចិត្តពីអង្គការស្ទែមកម្ពុជា ដែលអង្គការមួយនេះជ្រកក្រោមម្លប់នៃរាជរដ្ឋាភិបាលកម្ពុជា ក្នុងគោលបំណងបណ្ដុះបណ្ដាលឱ្យកុមារ និងយុវជនខ្មែរបានដោគជ័យនូវបំណងប្រាថ្នាក្នុងការរុករករបស់ពួកគេ។ អង្គការនេះបានផ្ដល់នូវបច្ចេកទេស ឯកសារ និងបទពិសោធន៍ជាច្រើនដល់ឧត្ដម ដែលធ្វើឱ្យឧត្ដមបានសម្រេចនូវគោលដៅរបស់គេ គឺក្លាយជាម្ចាស់គ្រងមេដាយមាសផ្នែកអ្នកស្រាវជ្រាវវ័យក្មេងមួយរូប ឈរលើជំនាញផលិតម៉ាស៊ីនថតរូបដែលមានសមត្ថភាពអាចចាប់រូបភាពនិងសម្លេងបានយ៉ាងច្បាស់នៅក្នុងទឹក។

ទីបំផុតជីវិតរបស់ក្មេងប្រុស **ឧត្ដម** ត្រូវបានផ្លាស់ប្ដូរទាំងស្រុងតាំងពីក្មេងដែលរៀនមិនពូកែដើរតែលេង ប្រែក្លាយជាវីរភាពវ័យក្មេងរបស់កម្ពុជាឈរលើឆាកអន្តរជាតិ បង្ហាញនូវទង់ជាតិខ្មែរដ៏ស្រស់សោភាទៅដល់មនុស្សទូទាំងសកលលោកបានស្គាល់។ ហើយនៅពេលដែលគេប្រឡប់មកកម្ពុជាវិញ **ឧត្ដម** បានចែករំលែកនូវបទពិសោធរបស់ខ្លួនទៅដល់ក្មេងៗឯទៀតដោយបញ្ជាក់ថា «អំណានមានឥទ្ធិពលប្រៀបដូចជាឱសថទិព្វ អំណានជាខ្យល់ដង្ហើមនៃជីវិតរបស់ជនទាំងពួង ដែលញ៉ាំងឱ្យពួកគេមានសេចក្ដីល្អ និងថ្លៃថ្នូរក្នុងខ្លួនយ៉ាងប្រសើរថ្លៃថ្លា»។

ការអានច្រើន បានធ្វើឱ្យ **ឧត្ដម** មានចំណេះប្រកបដោសេចក្ដីរុងរឿង និងសែនប្រសើរគាប់។ គេបានធ្វើឱ្យឪពុក និងលោគ្រូ អ្នកគ្រូ មានមោទនភាពលើរូបគេ ហើយគេក៏រស់នៅប្រកបដោយភាពសុខសាន្តចម្រើនរហូតរៀងទៅអើយ៕

## ជ័យលាភីលេខ៣ ផ្នែកតែងនិពន្ធ

## «ពានរង្វាន់សម្ដេចតេជោ ហ៊ុន សែន»

**អបអរសាទរ ទិវាជាតិអំណានលើកទី៥ ១១ មីនា ២០២០**

**យុវតី ភាន ស្រីនីត**

*ជាសិស្សថ្នាក់ទី ១១ នៃវិទ្យាល័យ មេសាង ខេត្តព្រៃវែង*

**ចំណងជើងកំណាព្យ៖ អំណានជាទ្រព្យដ៏ប្រសើរ**

(កំណាព្យបទ ពាក្យប្រាំពីរ)

១- នេះនឹងថ្លាថ្លែងថែរថី    បកស្រាយសេចក្ដីស្ដីប្រការ  
សិស្សវិទ្យាល័យស្រីសោមា    កើតក្នុងគ្រួសារមហាក្រ។

២- គ្មានប្រាក់កាសចាយវាយគ្រប់គ្រាន់    ចិញ្ចឹមទាមាន់គ្រាន់កំដរ  
បន្លែគ្រប់មុខទុកបន្ត    ជីវិតបវរដ៏ថ្លាថ្លៃ។

៣- ឆ្នាំថ្មីស្រីស្រស់បស់សោភី    ថ្នាក់ទីដប់ពីរទីប្រាថ្នា  
ដែលកែវកល្យាណបានសន្យា    ជាមួយមាតាថាខិតខំ។

៤- តស៊ូរៀនសូត្ររហូតដល់    ចប់ថ្នាក់សកលផលសក្តិសម  
ធ្វើគ្រូបង្រៀនមានអារម្មណ៍    ផ្សព្វផ្សាំចែកចំណេះសិស្សា។

៥- ព្រះសូរ្យរះខ្ពស់ហួសព្រឹកព្រៃ    ឯនភាល័យនៃវេហា  
ក្នុងបរិវេណនាសាលា    គេឃើញជីតាផ្កាក្រពុំ។

៦- អង្គុយក្រោមម្លប់ចន្ទន៍គិរី    សោមានៅទីក្រៅជំនុំ  
កំណត់គំនិតពិតចាស់ទុំ    សៀវភៅជាធំម៉ុមស្និទ្ធស្នេហ៍។

៧- នាងអានជក់ចិត្តភ្លេចគិតព្រួយ    ទំព័រមួយៗជួយនាំណែ  
នួននាងយល់ដឹងថ្លឹងថ្លែងដែរ    ចេះចាំហូរហែពូកែក្រៃ។

៨- អក្សរសាស្ត្រខ្មែរទីដប់ពីរ    សោមានារីអានរាល់ថ្ងៃ  
សៀវភៅផ្សេងទៀតផ្លៀតកែខៃ    អានឥតសំចៃដៃម្ដងណា។

៩- នាងតែងស្រមៃថ្ងៃណាមួយ    អំណានអាចជួយស្ទួយប្រាជ្ញា  
កកើតចំណេះចេះខ្លាំងក្លា    យិតយោងអាត្មាស្ពានជីវិត។

១០- កំពុងសញ្ជឹងនឹងការអាន    លោកគ្រូចំណានបានមកជិត  
សោមាធ្វើអ្វីស្ដីការពិត    ឯកោឥតមិត្តគិតអ្វីដែរ?

១១- សោមាលើកដៃជម្រាបសួរ    ទន់ភ្លន់សមគួរឥតឡប់ឡែ  
ចាស់កំពុងអានភាសាខ្មែរ    ត្រៀមសិស្សពូកែខែខាងមុខ។

១២- លោកគ្រូវាចាថាកូនស្រី    ហៅល្អឥតបីស្រីគ្រោងទុក  
ជាក់ចំជាត្រូវនូវទំនុក    អានអាចវាយលុកអវិជ្ជា។

១៣- ខ្មែរឬគណិតពិតប្រយោជន៍    កូនកុំបង្ហោចពេលវេលា  
ស្រាវជ្រាវគ្រប់មុខពុកជានា    ថាកូនពុំងាមានរស្មី។

១៤- អានច្រើនក្រវើនក្រើនរំលឹក
បង្ការភ្លាំងភ្លឹកនឹកជាថ្មី
បណ្ដុះបញ្ញាស្មារតី
ស្នេហាទឹកដីបុរីវង្ស។

១៥- អំណានអំណាចអាចកម្ចាត់
ទុកសោកវិបត្តិខ្វាត់វង្គាត់
សង្គមសុខសាន្តបានធំធាត់
អានអភិវឌ្ឍជាតិថ្កើនថ្កាន។

១៦- មន្ត្រីតូចធំហំកាយា
ជំទាវឧកញ៉ាវីឡាឡាន
សុទ្ធមានកំណើតកើតពីអាន
គឺអានហើយអានបានជោគជ័យ។

១៧- រីអ្នកខ្ជិលអានប្រានឱ្យល្ងង់
ធ្លាក់ក្នុងអន្លង់ផុងគ្រោះភ័យ
ខ្សត់ខ្សោយរបៀនគ្មានវាងវៃ
ជីវិតឥតន័យរស់វេងកម្ម។

១៨- លោកគ្រូចំណានបានឈប់ស្តី
សោមាប្រិមប្រិយស្រីស្រងាំ
ត្រង់ត្រាប់ពាក្យពេចន៍វេចចងចាំ
ដែលគ្រូផ្តែផ្តាំផ្តល់ឱវាទ។

១៩- លើកដៃសំពះព្រះទីពីរ
សោមានារីដ៏សែនឆ្លាត
អរគុណគ្រូពិតគិតសង្វាត
តែងតែឱហាតស្អាតចិត្តកាយ។

២០- កូននឹងខិតខំចំគោលដៅ
ប្រានភាពល្ងង់ខ្លៅទៅឱ្យឆ្ងាយ
អានរកទ្រឹស្ដីថ្មីទាំងឡាយ
អានមិននឿយណាចាយវិជ្ជា។

២១- ស្នូរជួងលាន់ឮព្រឹសោតា
នួននាងសោមាភ្ញាក់អង្គា
អរគុណអនន្តមហិមា
លោកគ្រូកូនលាគ្រានេះសិន។

២២- ដល់ម៉ោងត្រូវចូលបណ្ណាល័យ
នាងមាននិស្ស័យប្រសប់ប៉ិន
ខ្ចីសៀវភៅអានបានបំណិន
សម្រេចសុបិនដូចប្រាថ្នា។

២៣- រសៀលទន់ទេរជ្រេត្រជាក់
សៀវភៅជ្រៅរាក់ទាក់នេត្រា
ក្រោមខ្ទមក្រោមម្លប់ដើមសេដា
នួននាងសោមាអានជាថ្មី។

២៤- អានដោយញញឹមមិនខ្ជីខ្ជា
ពុទ្ធិហូរហៀរគ្រប់ទ្រឹស្ដី
ដោយទំនុកចិត្តឥតខ្លាចអ្វី
ដូចរាជសីក្នុងគុហា។

២៥- នាងមានចំណេះចេះចាំស្ទាត់
គ្រោងអនុវត្តតាមមាគ៌ា
បង្កើតអាជីពមហិមា
តាមក្បួនវគ្គឃ្លាក្នុងសៀវភៅ។

២៦- សោមាសង្ឃឹមយ៉ាងមុតមាំ
ផ្លែផ្កាជោគជាំនាំមកនូវ
សិរីសួស្តីតរៀងទៅ
ដោយអានសៀវភៅនៅថ្ងៃនេះ៕